ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ

សាលាខេត្តព្រៃវែង

លេខ ០១៥/សជណ/១១

# សេចក្តីជូនដំណឹង

## ស្តីពីការពន្ធលើប្រាក់បៀវត្ស

- បានឃើញប្រកាសលេខ ៣៩៦ ប្រក.សហវ.ពដ ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ១៩៩៧ ស្តីពីពន្ធលើប្រាក់បៀវត្ស។

អភិបាលនៃគណៈអភិបាលខេត្តសូមជូនដំណឹងថា៖

១- ពន្ធលើប្រាក់បៀវត្ស គឺជាពន្ធប្រចាំខែដែលបានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញសកម្មភាពបំរើការងារ។

២- មុខសញ្ញាប្រមូលពន្ធលើប្រាក់បៀវត្សមាន៖

ក- "និយោជក" រួមមាន ស្ថាប័នរដ្ឋ នីតិបុគ្គល់និវាសនជន ក្រុមអាជីវកម្មនិវាសនជន គ្រឹះស្ថានអចិន្ត្រៃយ៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា អង្គការមិនស្វែងរកចំណេញ ឬ រូបវន្តបុគ្គលនិវាសនជនដែលប្រកបអាជីវកម្ម។

ខ- "និយោជិត" សំដៅដល់រូបវន្តបុគ្គលដែលបានទទួលប្រាក់បៀវត្សអំពីសកម្មភាពរបស់ខ្លួន រួមបញ្ចូលទាំងមន្ត្រីរាជការ និង អ្នកទទួលខុសត្រូវ ឬ អភិបាលសហគ្រាសផង។

៣- ប្រាក់បៀវត្សជាប់ពន្ធចាប់ពី ៥០០.០០០៛ ឡើងទៅ។ ប្រាក់បៀវត្ស សំដៅដល់លាភការ ប្រាក់បំណាច់ បុព្វលាភ ប្រាក់ម៉ោងបន្ថែម ប្រាក់ប៉ះប៉ូវនានា និង អត្ថប្រយោជន៍បន្ថែម ដែលបានទូទាត់ឲ្យដល់និយោជិត ឬ ដែលបានទូទាត់ដើម្បីជាប្រយោជន៍ផ្ទាល់ ឬ ប្រយោលដល់និយោជិតចំពោះការបំពេញសកម្មភាពបំរើ។

៤- ការកំណត់ប្រាក់ពន្ធប្រចាំខែដែលត្រូវកាត់ទុក៖

ក- សម្រាប់និយោជិតនិវាសនជន ប្រាក់ពន្ធត្រូវបង់ ត្រូវកំណត់លើប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងត្រូវកាត់ទុកដោយនិយោជក តាមអត្រាកំណើនតាមថ្នាក់ដូចតទៅ៖

| ភាគបៀវត្សប្រចាំខែត្រូវជាប់ពន្ធ | អត្រាពន្ធ |
|---|---|
| ពី ០៛០០ ដល់ ៥០០.០០០៛០០ | ០% |
| ពី ៥០០.០០១៛០០ ដល់ ១.២៥០.០០០៛០០ | ៥% |
| ពី ១.២៥០.០០១៛០០ ដល់ ៨.៥០០.០០០៛០០ | ១០% |
| ពី ៨.៥០០.០០១៛០០ ដល់ ១២.៥០០.០០០៛០០ | ១៥% |
| លើសពី ១២.៥០០.០០០៛០០ | ២០% |

ខ- ចំពោះអត្ថប្រយោជន៍បន្ថែម ជារៀងរាល់ខែនិយោជកត្រូវកាត់ទុក និងបង់ប្រាក់ពន្ធតាមកាលកំណត់តាមអត្រា ២០ភាគរយ នៃតម្លៃសរុបអត្ថប្រយោជន៍បន្ថែម គឺជាតម្លៃទីផ្សាររួមទាំងពន្ធអាករទាំងអស់។

គ- សម្រាប់អ្នកជាប់ពន្ធអនិវាសនជន ប្រាក់ពន្ធត្រូវកាត់ទុកដោយអ្នកបើកប្រាក់ឲ្យ តាមអត្រា ២០ភាគរយ លើរាល់ការទូទាត់ប្រាក់បៀវត្សជាប់ពន្ធ។

៥- ភារកិច្ចរបស់និយោជក៖

ក- ការបើកបៀវត្សបង្កើតជាហេតុបណ្តាលឲ្យជាប់ពន្ធ។

ខ- ពន្ធលើប្រាក់បៀវត្សត្រូវប្រមូលតាមរបៀបកាត់ទុកជាមុន ជារៀងរាល់ខែដោយនិយោជក នៅរាល់ពេលបើកប្រាក់បៀវត្ស។

គ- ប្រាក់ពន្ធកាត់ទុកដែលទាក់ទងដល់ការបើកប្រាក់បៀវត្សធ្វើឡើងក្នុងខែណាមួយ ត្រូវបង់យ៉ាងយឺតបំផុតនៅថ្ងៃទី ១៥ នៃខែបន្ទាប់ ជូនទៅរដ្ឋបាលសារពើពន្ធនៅទីកន្លែងនៃលំនៅដ្ឋាន ឬ គ្រឹះស្ថានជាគោលដើមនៃអ្នកទទួលភារៈកាត់ទុកប្រាក់ពន្ធនោះ។

ឃ-គ្រប់និយោជនដែលបើកប្រាក់បៀវត្សត្រូវជាប់ពន្ធ ត្រូវទទួលបំពេញភារកិច្ចៈ

១- កាត់ទុកប្រាក់បៀវត្សមុនពេលបើកប្រាក់បៀវត្ស។

២- រាយការណ៍ជូនរដ្ឋបាលសារពើពន្ធ និងនិយោជិត អំពីស្ថានភាពប្រាក់ពន្ធដែលបានកាត់ទុក។

៣- កាន់កាប់ និងថែរក្សាបញ្ជីការដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ទទួលបាននូវសេចក្ដីជូនដំណឹងនេះ អភិបាលនៃគណៈអភិបាលខេត្តមានជំនឿថា គ្រប់អង្គការនានា គ្រប់អង្គភាព ពោលគឺ គ្រប់និយោជកទាំងអស់ដែលបើកប្រាក់បៀវត្សត្រូវជាប់ពន្ធ ត្រូវចាត់តាំងអ្នកទទួលភារៈកាត់ទុកប្រាក់ពន្ធ មកទំនាក់ទំនងជាមួយសាខាពន្ធដារខេត្ត ដើម្បីបំពេញកាតព្វកិច្ចប្រកាសបង់ពន្ធលើប្រាក់បៀវត្ស ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ជាមិនខានឡើយ។

ព្រៃវែង,ថ្ងៃទី ០១ ខែធ្នូ ឆ្នាំ២០១១

**អភិបាលនៃគណៈអភិបាលខេត្ត**

**អ៊ុង_សាមី**

**<u>កន្លែងទទួលៈ</u>**

- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានពន្ធដារ
- ក្រុមប្រឹក្សាខេត្តព្រៃវែង
  "គោរពជូនជ្រាប"
- សាលាស្រុក-ក្រុង
- មន្ទីជុំវិញខេត្ត
- សាខាពន្ធដារខេត្ត
- និងស្ថាប័នពាក់ព័ន្ធ
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ